ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង ស្តីពីការព្យួរកិច្ចសន្យាការងារ

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង០៤និង០០នាទីល្ងាច នៅក្នុងរោងចក្រផលិតស្បែកជើង ជួន លី អ៊ិនធើណេសិនណល ឯក

បានចុះកិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារជាមួយតំណាងសហជីពដើម្បីការពារសិទ្ធិកម្មករ សហជីពកម្មករកម្ពុជា និងសហជីពចលនាយុវជនដើម្បីសេរីភាព

ប្រចាំមូលដ្ឋាន ប្រចាំរោងចក្រផលិតស្បែកជើង ជួន លីដែលមានប្រការដូចខាងក្រោម៖

ប្រការ១៖ ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២០៥នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន ៦៧០នាក់ រយៈពេល ៥៩ថ្ងៃគិតចាប់ពីថ្ងៃទី០២ ខែមករា ដល់ថ្ងៃទី២៨ ខែកុម្ភ ឆ្នាំ២០២៣ដោយមូលហេតុគ្មានការបញ្ជាទិញ។

ប្រការ២៖ ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន៣០ដុល្លារអាមេរិកក្នុង១ខែ ក្នុងនោះ៖

-ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ

-ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ

-ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ

ដោយព្រមព្រៀងបើកជូននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២មុនការព្យួរកិច្ចសន្យាការងារ។

ខេត្តតាកែវ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២

តំណាងភាគីសហជីពមូលដ្ឋាន

តំណាងភាគីក្រុមហ៊ុន

នាយកក្រុមហ៊ុន